ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ............................

ថ្ងៃព្រហស្បតិ៍ ១១កើត ខែ ស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ២០១៨

# សេចក្តីជូនដំណឹង
## ស្តីពី
## ការប្រឡងប្រជែងជ្រើសរើសបេក្ខជនឱ្យចូលបម្រើការងារ ក្នុងក្របខណ្ឌក្រសួងរ៉ែ និង ថាមពល សម្រាប់ឆ្នាំ២០១៨

ក្រសួងរ៉ែ និង ថាមពលសូមជូនដំណឹងដល់មន្ត្រីរាជការ និស្សិត និង សាធារណជនឱ្យបានជ្រាបថា សម្រាប់ឆ្នាំ២០១៨នេះ ក្រសួងនឹងរៀបចំការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិល ក្របខណ្ឌថ្មី (**ប្រភេទ «ក»**) ចំនួន១១កន្លែង ឱ្យចូលបម្រើការងារ នៅតាមអង្គភាពនានាចំណុះក្រសួងរ៉ែ និង ថាមពល ទាំងនៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ។

### ១. មុខជំនាញជ្រើសរើស

- រ៉ែ ឬ ភូគព្ភសាស្ត្រ
- សេដ្ឋកិច្ច គណនេយ្យ ធនាគារ និង ហិរញ្ញវត្ថុ
- នីតិសាស្ត្រ ឬ រដ្ឋបាលសាធារណៈ

### ២. អង្គភាពដែលត្រូវជ្រើសរើសចូលបម្រើការងារ

*២.១ នៅទីស្តីការក្រសួង៖* ត្រូវការជ្រើសរើសចំនួន ០៥កន្លែង។

*២.២ នៅមន្ទីររ៉ែ និង ថាមពលខេត្ត៖* ត្រូវការជ្រើសរើសចំនួន ០៦កន្លែង តាមអង្គភាពដូចខាងក្រោម៖

| ល.រ. | អង្គភាពត្រូវការជ្រើសរើស | ចំនួន |
|---|---|---|
| ១ | មន្ទីររ៉ែ និង ថាមពលខេត្តកំពង់ស្ពឺ | ០១ កន្លែង |
| ២ | មន្ទីររ៉ែ និង ថាមពលខេត្តកំពត | ០១ កន្លែង |
| ៣ | មន្ទីររ៉ែ និង ថាមពលខេត្តកោះកុង | ០១ កន្លែង |
| ៤ | មន្ទីររ៉ែ និង ថាមពលខេត្តបាត់ដំបង | ០១ កន្លែង |
| ៥ | មន្ទីររ៉ែ និង ថាមពលខេត្តព្រះសីហនុ | ០១ កន្លែង |
| ៦ | មន្ទីររ៉ែ និង ថាមពលខេត្តប៉ៃលិន | ០១ កន្លែង |


លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥)២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥)២៣ ២១៩ ៥៨៤
#79-89,Pasteur Street(51),Sangkat Phsar Thmey3,Khan Daun Penh,Phnom Penh Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh